## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ..១០...អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង

*****

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១១ ខែមករា ឆ្នាំ២០០២

## សំរេច

**មាត្រា ១.-**

កំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មមួយនៅក្នុងភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ឈ្មោះថា តំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង ។

**មាត្រា ២.-**

តំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង មានទំហំ ៣៣៦.២៤ ហិកតា។ តំបន់ឧស្សាហកម្មនេះស្ថិតនៅក្នុងខ្សែបន្ទាត់ព្រំ A, B, C, D, E, F, G, H, I, J, K, L, M, N, O, P ហើយនិយាមការនៃចំណុចខ្សែបន្ទាត់ព្រំដីនេះ និង ប្លង់ទីតាំងដីមាននៅក្នុងឧបសម្ព័ន្ធ ដែលជាចំណែកភ្ជាប់ក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ផ្ទៃដីទាំងអស់ដែលនៅក្នុងបរិវេណតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុងដូចបានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិរបស់រដ្ឋ ហើយបែបបទនៃការរៀបចំ និង នីតិវិធីនៃការគ្រប់គ្រងតំបន់ឧស្សាហកម្មនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤.-**

រាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ព្រមទាំងឯកសារទាំងឡាយណា ដែលពាក់ព័ន្ធនឹងសិទ្ធិលើដីធ្លី ដែលស្ថិតក្នុងតំបន់ឧស្សាហកម្ម ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិង សំណង់ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមាន ប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ- កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០០២

## តារាងសម្រង់និយាមការនៃចំនុចព្រំប្រទល់

## តំបន់ឧស្សាហកម្មនាងគុក ខេត្តកោះកុង

| ល.រ | X(E) | Y(N) | ល.រ | X(E) | Y(N) |
|---|---|---|---|---|---|
| A | 275447.416 | 1287454.907 | I | 274269.627 | 1290391.330 |
| B | 275505.191 | 1287579.681 | J | 274176.384 | 1290326.579 |
| C | 275739.033 | 1287889.931 | K | 274032.695 | 1290110.221 |
| D | 275561.319 | 1289271.876 | L | 273936.415 | 1289100.759 |
| E | 275371.831 | 1289424.710 | M | 274036.828 | 1288391.130 |
| F | 274909.177 | 1289692.319 | N | 274065.285 | 1288106.150 |
| G | 274869.123 | 1289898.657 | O | 274338.553 | 1288154.008 |
| H | 274397.633 | 1290349.367 | P | 274348.719 | 1287955.143 |

## ប្លង់ទីតាំងដីតំបន់ឧស្សាហកម្មនាងគុក ខេត្តកោះកុង

